ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៤៧៧៦ អពដ

L202101070010 | TD3110

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃ ក្នុងកម្មវិធី "GDT Taxpayer App"

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយស សូមជម្រាបជូនសាធារណជន ឬម្ចាស់អចលនទ្រព្យជាអ្នកជាប់ពន្ធដែលមានអចលនទ្រព្យស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងក្រុងនៃខេត្តដែលជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យមេត្តាជ្រាបថា ក្នុងបរិបទនៃការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យពន្ធដារ ស្របតាមគោលនយោបាយកែទម្រង់របស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍមុខងារ សម្រាប់បង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃក្នុងកម្មវិធី "GDT Taxpayer App" ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាព និងតម្លាភាពលើកិច្ចការគ្រប់គ្រងការប្រមូលចំណូល ក៏ដូចជាក្នុងន័យបង្កលក្ខណៈឱ្យកាន់តែងាយស្រួល និងឆាប់រហ័សជូនម្ចាស់អចលនទ្រព្យក្នុងការបង់ប្រាក់ពន្ធតាមទូរស័ព្ទដៃដោយផ្ទាល់ ដោយមិនចាំបាច់អញ្ជើញទៅបង់ប្រាក់ពន្ធ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬតាមសាខាធនាគារពាណិជ្ជដែលជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារទៀតនោះឡើយ។ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាប និងណែនាំពីអត្ថប្រយោជន៍ និងរបៀបដំឡើងកម្មវិធីសម្រាប់បង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃដូចតទៅ÷

### I- អត្ថប្រយោជន៍នៃកម្មវិធីបង់ប្រាក់ពន្ធលើអចលនទ្រព្យលើទូរស័ព្ទដៃ

កម្មវិធីនេះនឹងបង្កលក្ខណៈងាយស្រួលដល់ម្ចាស់អចលនទ្រព្យជាអ្នកជាប់ពន្ធក្នុងការ÷

- ពិនិត្យមើលព័ត៌មានស្តីពីអចលនទ្រព្យដែលបានចុះបញ្ជី និងបានធ្វើបច្ចុប្បន្នភាពរួចរាល់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ
- បង់ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំរបស់ខ្លួន ដោយមិនចាំបាច់បំពេញព័ត៌មានក្នុងទម្រង់លិខិតប្រកាសពន្ធ
- ចំណេញពេលវេលា ដោយមិនចាំបាច់អញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬសាខាធនាគារពាណិជ្ជជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ
- មិនចាំបាច់ទៅកាន់សាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យនោះស្ថិតនៅ ដើម្បីធ្វើការផ្ទៀងផ្ទាត់បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ
- ទទួលបាននូវសេចក្តីជូនដំណឹងផ្សេងៗដូចជា÷ កាលបរិច្ឆេទនៃការប្រកាសបង់ពន្ធ កាលបរិច្ឆេទនៃការផុតកំណត់ការបង់ប្រាក់ពន្ធ ការប្រកាសបង់ប្រាក់ពន្ធខ្វះក្នុងការិយបរិច្ឆេទជាប់ពន្ធណាមួយ និងសេចក្តីជូនដំណឹងផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រភេទពន្ធនេះ។

### II- របៀបដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃ

ដើម្បីអាចប្រើប្រាស់កម្មវិធីបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃនេះ ម្ចាស់អចលនទ្រព្យអាចទាញយក និងដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃផ្ទាល់ខ្លួនដូចខាងក្រោម÷

- ***ចំពោះទូរស័ព្ទដៃដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការ Android÷*** សូមចូលទៅកាន់ "Play Store" រួចស្វែងរកពាក្យ "GDT Taxpayer App" បន្ទាប់មកទាញយក និងដំឡើងកម្មវិធីនេះនៅក្នុងទូរស័ព្ទដៃ
- ***ចំពោះទូរស័ព្ទដៃដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការ iOS÷*** សូមចូលទៅកាន់ "App Store" រួចស្វែងរកពាក្យ "GDT Taxpayer App" បន្ទាប់មកទាញយក និងដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃ។


អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh